# វិធីសាស្ត្រ និង ជំនាញសិក្សាព្រះគម្ពីរ

**ការដាក់ជំនួសឈ្មោះ ៖** ដើម្បីជួយអ្នកឲ្យភ្ជាប់គោលលទ្ធិ និងគោលការណ៍ទាំងឡាយមកពីបទគម្ពីរនៅក្នុងជីវិតរបស់អ្នក ចូរដាក់ឈ្មោះអ្នកជំនួសឈ្មោះដែលនៅក្នុងបទគម្ពីរទាំងឡាយ ។ សូមសាកល្បងប្រើជំនាញសិក្សាព្រះគម្ពីរនេះជាមួយនឹងឈ្មោះរបស់ពេត្រុសនៅក្នុង ម៉ាថាយ ១៦:១៥–១៧ ។

**បុព្វហេតុ និង លទ្ធផល ៖** ដើម្បីជួយអ្នកស្គាល់គោលការណ៍ទាំងឡាយនៃដំណឹងល្អនៅក្នុងបទគម្ពីរនានា សូមរកមើលពាក្យទំនាក់ទំនងគ្នា « ប្រសិនបើ-នោះ » និង « ពីព្រោះ-ហេតុដូច្នោះហើយ » ។ សូមសាកល្បងប្រើជំនាញនេះជាមួយនឹង ម៉ាថាយ ៦:១៤-១៥ ។

**បញ្ជីទាំងឡាយនៃបទគម្ពីរ ៖** ជាញឹកញាប់បទគម្ពីរ មាននូវបញ្ជីនៃរឿងដូចជា ការណែនាំ ឬការព្រមាន ។ នៅពេលអ្នករកឃើញបញ្ជីទាំងឡាយ សូមពិចារណាអំពីការដាក់លេខលើលក្ខខណ្ឌនីមួយៗ ។ សូមសាកល្បងប្រើជំនាញនេះជាមួយនឹង កាឡាទី ៥:២២-២៣ ។

**ភាពផ្ទុយគ្នា ៖** ជារឿយៗ បទគម្ពីរមានភាពផ្ទុយគ្នាពីគំនិត ព្រឹត្តិការណ៍ និង មនុស្ស ។ ការផ្ទុយទាំងនេះ គូសបញ្ជាក់អំពីគោលការណ៍ដំណឹងល្អ ។ ចូរស្វែងរកមើលភាពផ្ទុយគ្នានៅក្នុងខនានា ក្នុងជំពូកនានា និងជំពូកដែលទាក់ទងគ្នា និងគម្ពីរនានា ។ សូមសាកល្បងជំនាញនេះជាមួយនឹង ម៉ាថាយ ៥:១៤-១៦ ។

**ការនឹកគិតក្នុងចិត្ត ៖** សូមស្វែងរកការពិពណ៌នាលម្អិត ដែលអាចជួយអ្នកឲ្យបង្កើតរូបភាពក្នុងគំនិត ពេលអ្នកអាន ។ រូបភាពត្រូវបានបង្ហាញនៅព្រឹត្តការណ៍ជាក់លាក់នានា ។ ការណ៍នេះអាចជួយពង្រឹងទីបន្ទាល់របស់អ្នកអំពីភាពពិតនៃអ្វីដែលអ្នកអាននៅក្នុងបទគម្ពីរ ។ សូមសាកល្បងជំនាញនេះជាមួយនឹង ម៉ាថាយ ៨:២៣-២៧ ។

**ការប្រើជានិមិត្តសញ្ញា ៖** ពាក្យដូចជា *ដូច, ដូចជា* ឬ *ប្រៀបប្រដូច* អាចជួយអ្នកស្គាល់និមិត្តសញ្ញាទាំងឡាយ ។ សូមរកមើលឲ្យលើសពីនិមិត្តសញ្ញា តាមរយៈការរុករកលក្ខណៈធម្មជាតិរបស់វា ហើយសញ្ជឹងគិតអំពីចរិតលក្ខណៈរបស់វា ។ ជំនួយនានាសម្រាប់ការសិក្សាព្រះគម្ពីរ ដូចជាលេខយោង សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ អាចជួយអ្នកឲ្យបកស្រាយពីនិមិត្តសញ្ញាមួយចំនួនបាន ។ សូមសាកល្បងប្រើជំនាញសិក្សានេះជាមួយ ម៉ាថាយ ១៣:២៤-៣០ ។

**សេចក្តីយោងបទគម្ពីរ ៖** ជាញឹកញាប់ វគ្គបទគម្ពីរមួយអាចពន្យល់ ឬ បញ្ជាក់ច្បាស់នូវឃ្លា ឬ បរិបទមួយ ដែលមាននៅក្នុងវគ្គបទគម្ពីរផ្សេងទៀត ។ សូមតភ្ជាប់វគ្គបទគម្ពីរជាមួយគ្នា ដោយប្រើលេខយោង លិបិក្រម ឬ សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ដើម្បីជួយបង្ហាញអត្ថន័យនៃវគ្គបទគម្ពីរមួយ ។ សូមអនុវត្តជំនាញនេះដោយអាន យ៉ូហាន ១០:១៦ រួចរកមើលទំនាក់ទំនងរបស់វានឹង នីហ្វៃទី ៣ ១៥:២១ ។ តើការអាន នីហ្វៃទី ៣ ១៥:២១ ជួយអ្នកឲ្យយល់អត្ថន័យក្នុង យ៉ូហាន ១០:១៦កាន់តែប្រសើរឡើងដោយរបៀបណា ?

**ការពិចារណា ៖** ការពិចារណារួមបញ្ចូលទាំង ការគិត ការស្មឹងស្មាធ ការសួរសំណួរ និង ការវាយតម្លៃលើអ្វីៗដែលអ្នកដឹង និង អ្វីៗដែលអ្នកបានរៀន ។ ការពិចារណាជាញឹកញាប់ជួយយើងឲ្យយល់អំពីអ្វី ដែលយើងត្រូវធ្វើដើម្បីអនុវត្តគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ សូមពិចារណាពីរបៀបដែលអ្នកអាចអនុវត្តសេចក្តីពិតទាំងនេះនៅក្នុង ហេព្រើរ ១២:៩ ។

**ការអនុវត្ត ៖** នៅពេលអ្នកស្គាល់ ហើយយល់គោលលទ្ធិ និង គោលការណ៍ទាំងឡាយដែលមាននៅក្នុងព្រះគម្ពីរ អ្នកអាចទទួលបានចំណេះដឹងយ៉ាងជ្រាលជ្រៅដោយធ្វើតាមសេចក្តីពិតដែលអ្នកបានរកឃើញ ។ ព្រះយេស៊ូវគ្រីស្ទបានមានបន្ទូលថា « បើអ្នកណាចង់ធ្វើតាមព្រះហឫទ័យ[ របស់ព្រះវរបិតា ] នោះនឹងបានដឹងជាសេចក្តីបង្រៀននេះមកពីព្រះ ឬជាខ្ញុំនិយាយដោយអាងខ្លួនខ្ញុំ » ( យ៉ូហាន ៧:១៧ ) ។ សូមរកមើលឱកាសដើម្បីអនុវត្តអ្វីដែលអ្នករៀន ពេលអ្នកសិក្សាព្រះគម្ពីរដោយខ្លួនឯង ។



© ២០១៥ ដោយ Intellectual Reserve, Inc. រក្សាសិទ្ធិគ្រប់យ៉ាង ។